ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

សូមអបអរសាទរចំពោះការសម្រេចបានការបញ្ចប់ការសិក្សារបស់សិស្សលោកអ្នក! យើងសូមជូនពរឱ្យពួកគេមានអ្វីៗល្អៗ ហើយចង់ជួយធ្វើយ៉ាងណាឱ្យពួកគេមានអ៊ិនធឺណិតដែលអាចប្រើការបាន នៅពេលដែលពួកគេស្វែងរកឱកាសសិក្សាបន្ថែម ឬចូលធ្វើការងារ។

អរគុណចំពោះសកម្មភាពរបស់រដ្ឋាភិបាលរដ្ឋសហព័ន្ធ ឥឡូវនេះក្រុមគ្រួសារនៅហ្វីឡាដែលហ្វ្យ៉ាជាច្រើនអាចឆក់យកឱកាសក្នុងការជ្រើសរើសអ៊ិនធឺណិតដែលឥតគិតថ្លៃ ឬមានតម្លៃថោក។

**អត្ថប្រយោជន៍នៃប្រព័ន្ធភ្ជាប់កុំព្យូទ័រទៅអ៊ិនធឺណិតបន្ទាន់ (Emergency Broadband Benefit)**

បច្ចុប្បន្ននេះមានកម្មវិធី Emergency Broadband Benefit (EBB) របស់រដ្ឋាភិបាលរដ្ឋសហព័ន្ធ សម្រាប់អ្នកដែលត្រូវការជំនួយក្នុងការទទួលបាន ឬមានបណ្តាញអ៊ិនធឺណិតតទៅទៀត។

ក្រុមគ្រួសារដែលមានសិទ្ធិទទួលនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា អាចទទួល៖

- ការបញ្ចុះតម្លៃរហូតដល់ ៥០ ដុល្លារ ក្នុងមួយខែ សម្រាប់សេវាកម្មនៃប្រព័ន្ធភ្ជាប់កុំព្យូទ័រទៅអ៊ិនធឺណិត ហើយ
- ការបញ្ចុះតម្លៃម្តង រហូតដល់ ១០០ ដុល្លារ ដើម្បីទិញ កុំព្យូទ័រយួរបាន កុំព្យូទ័រដាក់លើតុ ឬថាបឡិត (tablet) ពីក្រុមផ្តល់សេវាកម្មដែលចូលរួម ប្រសិនបើក្រុមគ្រួសារជួយចេញ ១០ ដុល្លារ ទៅ ៥០ ដុល្លារ ទៅលើថ្លៃទិញ។

**កម្មវិធីប្រើអ៊ិនធឺណិតដោយឥតគិតថ្លៃសម្រាប់សិស្សក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា (PHLConnectED)**

ប្រសិនបើលោកអ្នកបានចុះឈ្មោះក្នុងកម្មវិធី PHLConnectED ហើយបច្ចុប្បន្ននេះគ្មានសិស្ស ថ្នាក់មុនមត្តេយ្យ-ថ្នាក់ទី១២ នៅក្នុងគ្រួសាររបស់លោកអ្នកដែលនឹងចូលរៀនវិញនៅឆ្នាំសិក្សា ២០២១-២០២២ សេវាកម្ម PHLConnectED របស់លោកអ្នកនឹងនៅបន្តរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

សិស្សានុសិស្សដែលបញ្ចប់ការសិក្សាដែលបានចុះឈ្មោះក្នុងកម្មវិធី PHLConnectED ក៏អាចជ្រើសរើសយកអត្ថប្រយោជន៍ពីកម្មវិធី Emergency Broadband Benefit (EBB) ដែលជាអត្ថប្រយោជន៍បណ្តោះអាសន្ន ដើម្បីជួយគ្រួសារឱ្យប្រើអ៊ិនធឺណិត ឬបន្តអ៊ិនធឺណិតរបស់ពួកគេ។ អត្ថប្រយោជន៍នេះអាចពាក់ព័ន្ធនឹងសេវាកម្ម Internet Essentials ដែលមានស្រាប់ ឬសេវាកម្មនៃប្រព័ន្ធភ្ជាប់កុំព្យូទ័រទៅអ៊ិនធឺណិតផ្សេងទៀត រួមទាំង ប្រព័ន្ធប្រើទូរស័ព្ទដៃដែលតភ្ជាប់ទៅសេវាកម្មផ្សេងទៀតដើម្បីអាចប្រើអ៊ិនធឺណិតបាន (hotspot data plans)។

**យើងជម្រុញក្រុមគ្រួសារទាំងអស់ឱ្យទាក់ទងទៅ Digital Navigator នៅថ្ងៃនេះ ដើម្បីស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍នៃ Emergency Broadband Benefit និងការណែនាំពីវិធីចុះឈ្មោះចូលរួម។**

សូមអរគុណ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា